ការសំភាសន៍របស់បងប្រុស ប៉ាង ស៊ុយ

ក៖ អ្នកដែលសំភាសន៍ កែវ សុម៉ាលី ខ៖ អ្នកដែលត្រូវគេសំភាសន៍ ប៉ាង ស៊ុយ

ការសង្ខេបរបស់បងប្រុស ប៉ាង ស៊ុយ

បងប្រុសប៉ាង ស៊ុយ
គាត់ត្រូវបានឱពុកស្លាប់ចោលក្រុមគ្រួសារនៅតាំងពីឆ្នាំ១៩៨០
ហើយម្តាយរបស់គាត់ត្រូវរវ៉ាប់រងសំរាប់គ្រួសារទាំងអស់
ហើយបងប្រុសគឺជាអ្នកដែលគំរូម្នាក់ដែលជីវិតរបស់គាត់គាត់តែងតែខិតខំតស៊ូ
នៅក្នុងការរៀនសូត្រហើយដោយសារគាត់មានសមត្ថភាពក្រសួងអប់រំបានបញ្ជូន
គាត់ទៅប្រជុំនៅប្រទេសម៉ាឡេស៊ីរយ:ពេលជិតមួយខែ។បងប្រុសបានរៀបការហើ
យមានកូនពីរនាក់
ហើយទោះឥឡូវគាត់មានអាយុ៤០ឆ្នាំហើយក៏ដោយក៏គាត់នៅតែបន្តការសិក្សារៀ
នភាសាអង់គ្លេសបន្ថែមដើម្បីក្រុមគ្រួសារនឹងបង្កើនចំនេះវិជ្ជា។
សព្វថ្ងៃបងប្រុសគាត់រស់នៅខណ្ឌសែនសុខហើយគាត់មានមុខរបរជាគ្រូបង្រៀន។

ក៖ សកល សកលវិទ្យាវិទ្យាល័យ៊ីប៊ី រ៉ាយ យូ
នៅសហរដ្ឋអាមេរិចកំពុងតែធ្វើកំរោងមួយបានយល់ដឹងពីក្រុមគ្រួសាររបស់យើង
នឹងក្រុមគ្រួសារនៅក្នុងប្រទេសកម្ពុជា
ថ្ងៃនេះខ្ញុំបានសំភាសន៍មិត្តរួមថ្នាក់ខ្ញុំម្នាក់ដែលហើយដែលគាត់នឹងចែកចាយពី
ក្រុមគ្រួសាររបស់គាត់ហើយតើបងតើញ៉ុមអាចសុំសិទ្ធដើម្បីសួរសំនួរខ្លះៗអំពីក្រុម
គ្រួសាររបស់បងខ្លះតើបានទេ?
ខ៖បាទបាទ!!
ក៖
អ៊ីចឹងតើអពួកយើងអាចសុំបងថាដើម្បីដាក់ចូលទៅក្នុងសកលវិទ្យាល័យរបស់យើ
ងបានអត់?
ខ៖ បាទអាចដាក់បាន។
ក៖ អ៊ីចឹងបងសុំសួរមួយ តើបងមានឈ្មោះអ្វីដែរ?
ខ៖ បាទខ្ញុំឈ្មោះ ប៉ាង ស៊ុយ។
ក៖ ប៉ាង ស៊ុយ!! អ៊ីចឹងបងតើសព្វថ្ងៃនេះបងរស់នៅឯណាដែរបង?
ខ៖ សព្វថ្ងៃនេះខ្ញុំរស់នៅខណ្ឌសែនសុខ រាជធានីភ្នំពេញ។
ក៖ អ៊ីចឹងបងតើបងរៀបការហើយរឺនៅ?
ខ៖ ខ្ញុំរៀបការរួចហើយ។
ក៖ តើបងមានកូនប៉ុន្មាននាក់ហើយ?
ខ៖ ខ្ញុំសព្វថ្ងៃមានកូន២នាក់។
ក៖ ហើយសព្វថ្ងៃបងមានអាយុប៉ុន្មានហើយបង?
ខ៖ សព្វថ្ងៃខ្ញុំមានអាយុ៤០ឆ្នាំ។
ក៖ ៤០ឆ្នាំ!!បងអាចចែកចាយខ្លះៗថាតើប្រពន្ធបងមានឈ្មោះអីដែរ?
ខ៖ បាទប្រពន្ធខ្ញុំឈ្មោះប៉ែនវណ្ណសុខលីន។
ក៖ អញ្ជឹងតើគាត់ប្រកបមុខរបរអីគេដែរបង?
ខ៖ គាត់ជាគ្រូបង្រៀន។
ក៖ អញ្ជឹងតើកូនបងមានអាយុប៉ុន្មាន?
ខ៖ កូនខ្ញុំបងមានអាយុ៦ឆ្នាំនឹងទី២មានអាយុ៣ឆ្នាំ។
ក៖ បងសព្វថ្ងៃបងប្រកបរបរអីគេដែរបង?
ខ៖ ខ្ញុំសព្វថ្ងៃជាគ្រូបង្រៀនដែរ។
ក៖ បងជាគ្រូបង្រៀនដែរ
។បងអើរទាក់ទងទៅនឹងអើរបងរៀបការហើយអ៊ីចឹងតើការរៀបការហ្នឹងតាមរ
យ:ឱពុកម្តាយជាអ្នករៀបចំឬក៏យើងស្រលាញ់គ្នាហើយបានរៀបការ?

ខ៖
បាទតាមពិតទៅតាមរយៈអាពាហ៍ពិពាហ៍របស់ខ្ញុំចាប់ផ្តើមដោយពួកយើងរៀបចំ
ទាំងពីរនាក់ប៉ុន្តែក្រោយពីយើងបានស្គាល់គ្នាយើងត្រូវអើរស្រលាញ់គ្នាហើយ
គឺក៏មានការព្រមព្រៀងពីឪពុកម្តាយទាំងសងខាងដែរ!!បាទ!!
ក៖ចា៎អ៊ីចឹងបងបានរៀបការស្របតាមពេញច្បាប់
បងទាក់ទងទៅនឹងក្រុមគ្រួសារយើងទៅនឹងបងកាលពីក្មេងតើបងមានឈ្មោះ
ខាងក្រៅទេបង?
ខ៖ បាទញ៉ាមអត់មានឈ្មោះអីទៀតទេញ៉ាមមានឈ្មោះហ្នឹងតែមួយគត់។
ក៖ មានឈ្មោះហ្នឹងតែមួយគត់។
អ៊ីចឹតងបងក្រៅពីរៀនតើក្រៅពីភាសាខ្មែរតើបងចេះភាសាអីគេផ្សេងទៀត?
ខ៖ អើរញ៉ាមចេះភាសាអង់គ្លេសហើយនឹងភាសាបារាំងបន្តិចបន្តួច។
ក៖ ចា!!អញ្ចឹងបងតើការសរសេរភាសាខ្មែររបស់បងយ៉ាងម៉េចដែរបង?
ខ៖
បាទការសរសេរភាសាខ្មែររបស់ខ្ញុំបានល្អតែមិនមែនជាល្អអីណាស់ណាទេបានព្រោះ
អីយើងមិនមែនជាអ្នកនិពន្ធប៉ុន្តែបើនិយាយពីអត្ថន័យយល់ដឹងនៃពាក្យខ្មែរញ៉ាំ
មយល់បានច្រើនព្រោះអីបានគឺខ្ញុំជាគ្រូបង្រៀនស្រាប់។
ក៖
អ៊ីចឹងចង់អោយបងចែកចាយនឹងភាសាទាក់ទងទៅនឹងការដែលបងរៀនភាសា
អង់គ្លេសហ្នឹង ថាតើបងអាចយកទៅប្រើប្រាស់បានអ្វីខ្លះសំរាប់ជីវភាពប្រចាំថ្ងៃ?
ខ៖
តាមរយៈភាសាអង់គ្លេសហ្នឹងវាខុសជំនាញរបស់ខ្ញុំប៉ុន្តែខ្ញុំចង់បង្កើនចំនេះវិជ្ជារបស់ខ្ញុំ
ខ្ញុំចង់អភិវឌ្ឍន៍ខាងផ្នែកភាសារបស់ខ្ញុំគឺខ្ញុំខំប្រឹងមករៀនភាសាអង់គ្លេសនៅថ្ងៃ
សៅរ៍នឹងថ្ងៃអាទិត្យតែក៏សំណាងដែរ
ខាងការងាររបស់ខ្ញុំចេះភាសាអង់គ្លេសគេក៏ជំរុញខ្ញុំអោយទៅប្រជុំនៅប្រទេសម៉ា
ឡេស៊ី
អញ្ចឹងបានន័យថាខ្ញុំអាចយកទៅប្រើការបានដែលចូលរួមប្រជុំទាំង១១ប្រទេស
នៅឯប្រទេសម៉ាឡេស៊ីរយៈពេល១ខែនេះចាត់ទុកថាជាជោគជ័យញ៉ាមមួយដែរដែ
លញ៉ាមខិតខំរៀនភាសាអង់គ្លេស។
ក៖ តើបងទៅចូលរួមប្រជុំនៅខែណាដែរបង?
ខ៖ បាទខ្ញុំទៅចូលរួមប្រជុំនេះកាលពេលថ្មីៗនេះដែរ
កាលពីខែថ្ងៃខ្ញុំចេញដំណើរពីប្រទេសកម្ពុជានៅថ្ងៃទី០៣ហើយត្រលប់មកប្រទេស
កម្ពុជាវិញនៅថ្ងៃទី៣០ខែមេសាឆ្នាំ២០១៦នេះឯង!!
ក៖
អញ្ចឹងទាក់ទងទៅនឹងក្រុមគ្រួសាររបស់បងតើញ៉ាមអាចសួរថាបងមានបងប្អូនប៉ុ
ន្មានៗនាក់ដែរ?
ខ៖ ខ្ញុំមានបងប្អូន៧នាក់។
ក៖ ស្រីប៉ុន្មានប្រុសប៉ុន្មានដែរបង?
ខ៖ ស្រីអើរ៤ប្រុស៣។
ក៖ ស្រី៤ប្រុស៣?ខ៖បាទ!!ក៖
ពួកគាត់នៅតើពួកគាត់ទាំងអស់នៅរស់សព្វថ្ងៃឬក៏ម៉េចដែរ?
ខ៖ បាទពួកគាត់នៅរស់សព្វថ្ងៃ។
ក៖
បងទាក់ទងទៅនឹងឪពុកម្តាយរបស់បងហាបងតើពួកគាត់មានឈ្មោះអីគេដែរ
បង?
ខ៖ បាទឪពុករបស់ខ្ញុំមានឈ្មោះប៉ាង សុខ។
ក៖ ឥឡូវគាត់ម៉េចហើយ?

ខ៖ ប៉ុន្តែគាត់បានស្លាប់នៅឆ្នាំ១៩៨០ក្រោយពេលបែកប៉ុល ពត
បន្ទាប់ពីពេលដែលរបបប៉ុល
ពតបានដួលរលំទៅបានចូលរបបរដ្ឋកម្ពជាវិញគាត់បានស្លាប់នៅសល់តែម្តាយ
របស់ខ្ញុំគាត់នៅមេម៉ាយ
ដែលគាត់រស់នៅជាមេម៉ាយរហូតមកដល់សព្វថ្ងៃដែលគាត់មានឈ្មោះថាអ៊ីឡាង
អ៊ីឡាង ម្តាយរបស់ខ្ញុំ។
ក៖ សព្វថ្ងៃនេះម្តាយរបស់បងមានអាយុប៉ុន្មានហើយ?
ខ៖ បាទម្តាយរបស់ខ្ញុំមានអាយុ៧៧ឆ្នាំហើយ។
ក៖ តើគាត់ម៉េច?
ខ៖ គាត់នៅរស់សព្វថ្ងៃតែគាត់ជរាហើយ។
ក៖ អ៊ីចឹងទាក់ទងទៅនឹងឪពុកម្តាយរបស់បង
ដោយសារឪពុករបស់បងគាត់បានស្លាប់អ៊ីចឹងតើម្តាយរបស់បងបានចែកចាយ
រឿងអីគេខ្លះដល់បងនៅពេលដែលយើងនៅក្មេងហ៊ានតើគាត់មានដែលប្រាប់អីគេ
ខ្លះអំពីឪពុករបស់បងទេ?
ខ៖ បាទគាត់ សំនួរនេះចង់សួរថាចង់ចែកចាយពីអ្វីរឿងអ្វី?
ក៖ចំ!ពីឪពុករបស់បងហ៊ានបង!!
ខ៖ ពីការរកស៊ីឬក៏រឿងអ្វី?
ក៖ ពីអត្តចរិកគាត់!!
ខ៖ ការសិក្សា!!
ក៖ ការសិក្សាអីអ៊ីចឹងហ៊ា??ម្តាយបងបានប្រាប់អីគេខ្លះដល់បងអត់?
ខ៖ បាទបាននិយាយខ្លះអំពីការសិក្សាថាឪពុករបស់ខ្ញុំគឺជាជាងអ៊ីនជីនៀ!!
ក៖ វិស្វករហី?
ខ៖ គាត់វិស្វករ ខាងផ្នែកសំនង់!!ក៖ចំ!!ខ៖ គាត់ជាអ្នកម៉ៅការ
ម៉ៅការតាំងពីមុនមក។ក៖ហ៊ី!!ខ៖
បាទហើយប្រាប់មុខរបរគាត់តែប៉ុណ្ណឹង!!ក៖ចំ!!ខ៖ហើយដល់គាត់ធ្វើការហ្នឹងទៅ។
បាទ!!
ក៖ ហើយគាត់ចរិកគាត់ម៉េចដែរ?
ខ៖បាទឪពុកស្លូតណាស់គាត់មិនដែលទៅណាមានថ្នឹចោលប្រពន្ធកូន
គាត់តែងតែមើលខុសត្រូវប្រពន្ធកូននឹងក្រុមគ្រួសារទាំងអស់បាទគាត់មិនដែល
ប្រព្រឹត្តអំពើពាលាផ្តេសផ្តាសឬក៏អ្វីដែលជាខុសច្បាប់គាត់មិនដែលធ្វើទេ!!
ក៖
អ៊ីចឹងបងបានដឹងថាឪពុកម្តាយរបស់បងគាត់ដែលចែកចាយទាក់ទងនឹងតា
យាយ?
ខ៖សុំម្តងទៀតសំនួរ?
ក៖
ញ៉ាមចង់សួរថាឪពុកម្តាយរបស់បងដែលប្រាប់ថាឪពុករបស់ឪពុករបស់បងហ្ការ
បងហ្ការគាត់មានដែលប្រាប់ថាមានឈ្មោះអីគាត់នៅឯណា?
ខ៖ គាត់ប្រាប់ថាជីតារបស់ខ្ញុំហ្នឹងគាត់ឈ្មោះកុងក្រុយ។
ក៖ កុង ក្រុយ!!
ខ៖ បាទហើយថាយាយរបស់ខ្ញុំហ្នឹងគាត់ឈ្មោះយាយយ៉ីន យាយយ៉ីន!!
ក៖យាយយ៉ីន!!
ខ៖ បាទគឺគាត់រស់នៅក្នុងស្រុកព្រៃឈរខេត្តកំពង់ចាម!!
ក៖ ស្រុកកំពង់ចាម?
ខ៖ស្រុកព្រៃឈើខេត្តកំពង់ចាម!!
ក៖ តាយាយបងគាត់ទទួលអនិច្ចកម្មនៅឆ្នាំណាដែរបង?
ខ៖ ញ៉ាមអត់បានដឹងផង ព្រោះអីគាត់ប្រហែលជាស្លាប់យូរហើយ បាទ!!

ក៖ អត់ដឹងអំពីជាក់លាក់ទេ អ៊ីចឹងបែរមកសួរ
បែរមកសួរអំពីអើរតាយាយខាងម្តាយរបស់បងវិញតើបងដឹងឈ្មោះរបស់ពួកគាត់
ទេបង?
ខ៖ បាទបើតាយាយខាងម្តាយរបស់ខ្ញុំតាអើរគាត់ឈ្មោះអើរ តា!
បងម៉ាគាត់ឈ្មោះម៉ាហួត!!ក៖ហ៊ឺ!!ខ៖បាទបើឪពុក
ឪពុករបស់ម្តាយរបស់ខ្ញុំគាត់ឈ្មោះអើរគាត់ឈ្មោះអើរ
ហែដូចភ្លេចហើយ!!ក៖ចា!ខ៖ បាទសុំទោស!!
ក៖ ចាអត់អីទេបង!!
អ៊ីចឹងបងអាចដឹងខ្លះៗទេបងថាម៉ាហើយនឹងតារបស់បងខាងម្តាយថាគាត់រស់
នៅណា?
ខ៖ គាត់រស់នៅស្រុកពញ្ញពុខេត្តកណ្តាល។
ក៖ ខេត្តកណ្តាល?
ខ៖បាទ!!
ក៖
គាត់មានដែលប្រាប់អំពីប្រវត្តិក្រុមគ្រួសារការប្រកបរបរអំពីតាយាយរបស់បងទេ
បង?
ខ៖
គាត់ប្រាប់ថាយាយតាញ៉ុមកាលពីដើមឡើយគាត់ជាអ្នករកស៊ីឈើនៅខេត្តពោធ៍
សាត់
គាត់ដើរក្នុងព្រៃដើម្បីដើររកទិញឈើក្រអូបដែលមានទិញពីអ្នកភូមិដែលរស់នៅ
ក្នុងខេត្តពោធ៍សាត់យកលក់
ក្រោយមកទៀតគាត់បានបង្កើតអោយមានម៉ាស៊ីនកិនស្រូវអោយបងប្អូនម្តាយរ
បស់ខ្ញុំហ្នឹងកូនៗបងរបស់ម្តាយរបស់ខ្ញុំហ្នឹងម្នាក់ៗមួយតែម្តាយខ្ញុំគាត់អត់មានបា
នអោយទេដោយសារគាត់រៀបការបែកដោយសារគាត់រៀបការជាមួយឪពុករបស់
ខ្ញុំនេះបាទ!!ហើយក៏បានបែក
ក្រោយពីពេលដែលម្តាយខ្ញុំបានរៀបការហើយគាត់ក៏សុំបែកពីឪពុកម្តាយមករស់
នៅទីក្រុងភ្នំពេញហ្នឹងជាមួយប៉ារបស់ខ្ញុំរហូតមកដល់ពេលនេះបាទ។
ក៖ អ៊ីចឹងបងតើបងធ្លាប់ទៅលេងតាយាយនៅខេត្ត?
ខ៖ បាទ
តាយាយរបស់ខ្ញុំគាត់បានស្លាប់យូរណាស់ហើយដូច្នេះខ្ញុំមិនអាចកើតទាន់ទេ !!
ក៖ហ្ហ៉អ៊ីចឹងបងកើតអត់ទាន់ទេបង?ខ៖បាទបាទ!!ក៖
អ៊ីចឹងប្រហែលជាគាត់ទទួលអនិច្ចាកម្មពេលណា?
ខ៖ សង្គមរាស្ត្រនិយម។
ក៖ សង្គមរាស្ត្រនិយមហេ?
ខ៖ បាទបាទ!!
ក៖ ចុះអ៊ីចឹងឥទ្ធ្យវទាក់ទងទៅនឹងម្តាយរបស់បង
នៅពេលដែលបងរស់នៅជាមួយម្តាយហ៉ាតើម្តាយរបស់បងបានបង្រៀនបងអីគេ
ខ្លះទាក់ទងទៅនឹងពេលហ្នឹងដូចជាការរស់នៅប្រចាំថ្ងៃ
ទាក់ទងទៅនឹងការរៀនសូត្រឬក៏ធ្វើជាមនុស្សល្អម៉េចបង?
ខ៖
បាទនៅក្នុងការរស់នៅរបស់ក្រុមគ្រួសាររបស់ខ្ញុំម្តាយរបស់ខ្ញុំតែងតែអប់រំអោយខ្ញុំ
ចេះខិតខំនៅក្នុងការតស៊ូគាត់បានប្រាប់ហើយថាគាត់ជាស្ត្រីមេម៉ាយមានកូនៗ
នាក់ចិញ្ចឹមរស់នៅក្នុងបន្ទុកអ៊ីចឹងគាត់តែងតែទូន្មានខ្ញុំអោយខ្ញុំខិតខំរៀនសូត្រ
ដើម្បីអោយខ្ញុំមានការងារធ្វើដើម្បីចិញ្ចឹមជីវិតខ្លួនឯងនឹងជួយក្រុមគ្រួសារយើង
ហើយជាពិសេសទៀតគឺអោយខ្ញុំកុំដើរលេងផ្តេសផ្តាសនឹងប្រព្រឹត្តអំពើរណាមិនគួរ
គប្បីនៅក្នុងសង្គមដែលគេស្អប់ខ្ពើម។ក៖ៈហ៊ឺ!!ខ៖

បាទអ៊ីចឹងខ្ញុំបានអនុវត្តតាមគាត់រហូតទាល់តែខ្ញុំបានទទួលការងារធ្វើនឹងខិត
ខំប្រឹងប្រែងខ្លួនឯងរៀនមកដល់សព្វថ្ងៃហ្នឹងឯង!!បាទ!!
ក៖
ចំ៉ាអញ្ចឹងបងញ្ចឹមចង់សួរមួយទាក់ទងទៅនឹងឪពុកម្តាយជីដូនជីតារបស់បងគឺ
ថាពួកគាត់កើតនៅក្នងប្រទេសកម្ពុជាហ្នឹងម៉ងគាត់អត់មានថាគាត់ចំណាកស្រុ
កមកពីក្រៅប្រទេសអីទេបងណោះ?
ខ៖បាទគាត់គឺជាជនជាតិខ្មែរគាត់រស់នៅប្រទេសកម្ពុជាសុទ្ធតែម្តងបាទ!!
ក៖
ចំ៉ាអរគុណបង។អ៊ីចឹងតើម៉ាការបស់បងគាត់ដែលធ្លាប់ទៅដើរលេងក្រៅប្រទេស
ទេបង?
ខ៖ អត់ទេគាត់មិនដែលទេម្តាយរបស់ខ្ញុំ។
ក៖អត់ដែលទៅទេបងណោះ?នៅពេល ដែល
អើរញ្ចឹមចង់សួរទាក់ទងទៅនឹតងការសិក្សារបស់បងពេលនៅក្មេងបន្តិច
ការសិក្សារបស់នៅពីក្មេងហាកាលពេលបងរៀនថ្នាក់ទីមួយហាតើបងមានលុយប៉ុ
ន្មានដើម្បីទៅរៀន?
ខ៖ អើរកាលពេលថ្នាក់ទី១មួយញ្ចឹមអត់បានរៀនផងញ្ចឹមដើរអើតតាមបង្អួច។
ក៖ ដើរអើតតាមបង្អួច?
ខ៖ បាទ!!
ញ្ចឹមឃើញគេសរសេរអក្សរញ្ចឹមបានមកសរសេរនៅផ្ទះធ្វើនៅផ្ទះ!!ក៖ហ៊ឺ!!ខ៖
ដល់ពេលថ្នាក់ទី២ញ្ចឹមមកចូលរៀននៅថ្នាក់ទី២តែម្តង។ក៖ហ្ហ៉!!ខ៖បាទ!!
ក៖ ម៉េចកាលហ្នឹងម៉េចបានបងអត់ចូលរៀននៅថ្នាក់ទី១?
ខ៖ ព្រោះញ្ចឹមមើលទៅគេឃើញញ្ចឹមមិនទាន់ត្រប់អាយុ!!ក៖ចំ៉ា!!ខ៖
បាទដល់ហើយឥឡវមកដល់សព្វថ្ងៃហ្នឹងក៏ញ្ចឹមបន្ថែមអាយុដែរធ្វើការសព្វថ្ងៃដើម្បី
បានធ្វើការ។
ក៖ហ្ហ៉យល់!!ខ៖បាទ!!ក៖ ចំ៉ាអ៊ីចឹងបង
បងមានចាំទេថាកាលបងរៀននៅពេលបឋមហ្នឹងសាលាបឋមសិក្សាមានឈ្មោះអី
ដែរ?
ខ៖
បាទនៅពេលដែលញ្ចឹមរៀនហ្នឹងសាលាបឋមសិក្សារបស់ខ្ញុំហ្នឹងគឺសាលាបឋមសិក្សា
ភ្នំពេញថ្មី ភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ
នៃប្រទេសកម្ពុជា។
ក៖ អញ្ចឹងសំរាប់សាលាដែលបងសិក្សានៅបឋម អនុវិទ្យាល័យ?
ខ៖ បាទ កាលពីញ្ចឹមរៀនអនុវិទ្យាល័យញ្ចឹមរៀននៅសាលាអនុវិទ្យាល័យ១០០ខ្នង
ពេលញ្ចឹមរៀននៅវិទ្យាល័យញ្ចឹមរៀននៅវិទ្យាល័យទួលទំពូង។ក៖ចំ៉ា!!ខ៖បាទ!!
ក៖ បង បងបានឆ្លងកាត់វគ្គបណ្តុះបណ្តាលជាគ្រូបង្រៀននៅឯណាដែរបង?
ខ៖ វគ្គបណ្តុះបណ្តាលគ្រូបង្រៀនញ្ចឹមនៅសាលាបឹងត្របែក។
ក៖នៅបឹងត្របែក?
ខ៖ បាទ!!
ក៖
អ៊ីចឹងកាលពេលបងប្រលងជាប់គ្រូហ្នឹងបងប្រលងជាប់នៅឆ្នាំណាដែរបងចាំទេប
ង?
ខ៖ ញ្ចឹមប្រលងជាប់គ្រូនៅឆ្នាំ១៩៩៣។
ក៖ ៩៣(១៩៩៣)?ខ៖បាទ!!ក៖ យូរមែន!!
អ៊ីចឹងកាលប្រលងនៅសម័យហ្នឹងតឹងទេបង?
ខ៖
កាលប្រលងឆ្នាំហ្នឹងបេក្ខជន៥០០នាក់គេយក១៥០នាក់អ៊ីចឹងហើយបាទចាត់ទុក
ថាតឹងឬមិនតឹងញ្ចឹមមិនដឹងម៉េចដែរបាទ!!

ក៖ ចំាពេលហ្នឹងពេលដែលបងជិះទៅរៀននៅសាលាបឹងត្របែកហ្នឹងហ៉ាបានអី
បានអីធ្វើជាមធ្យោបាយទៅហ៉ាបង?
ខ៖ កាលហ្នឹងគេអត់អោយធ្វើដំនើរទៅផង អោយដេកនៅអង់គេវិសិទ្ធ!!ក៖ចំា!ខ៖
បានន័យថាស្នាក់នៅក្នុងកន្លែងរៀន!!ក៖ចំា!ខ៖ស្នាក់នៅកន្លែងរៀនទៅរៀន!!
នៅពេលនោះរដ្ឋគេឧបត្ថម្ភអោយយើង!!
ក៖ចំា
អញ្ចឹងបងចាប់ផ្តើមនៅក្នុងហ្នឹងបងចាប់ផ្តើមនៅជាក្រុមៗអញ្ចឹងបងនៅជាមួយ
មនុស្សច្រើនជុំគ្នា តើមានឧបសគ្គអីគេទេបង?
ខ៖ ឧបសគ្គមនុស្សរស់នៅច្រើនជុំគ្នាមានឧបសគ្គ
តែបើមនុស្សយើងចេះសំរបសំរួលចេះរស់នៅការអើរបានរស់នៅចុះសំរុងជាមួយគ្នា
វាអត់មានឧបសគ្គអីទេចំពោះខ្ញុំ!!
ក៖ចំាអរគុណបង!!អញ្ចឹងបងបងបានចែកចាយបានខ្លះៗអញ្ចឹងបងពីមុនហើយ
នឹងឥឡូវបងប្រៀបធៀបជីវិតបងកាលពីមុនហើយឥឡូវមានការផ្លាស់ប្តូរច្រើន
ទេសំរាប់ជីវិតរបស់បង?
ខ៖
បាទកាលពីមុនញ្ញ៉ាមអត់ចេះភាសាអង់គ្លេសតែដល់ឥឡូវខ្ញុំចេះភាសាអង់គ្លេសហើ
យអើរហើយបន្ទាប់មកទៀតពេលមុនញ្ញ៉ាមមិនសូវមានការយល
ដឹងច្រើនតែដល់តែឥឡូវញ្ញ៉ាមរៀងមានការងារធ្វើទៅស្រុកក្រៅអ៊ីចឹងទៅទៅយើញ
ប្រទេសគេមានការអភិវឌ្ឍន៍ធ្វើអោយខ្ញុំមានចំនេះដឹងច្រើនហើយធ្វើអោយខួរ
ក្បាលខ្ញុំមានចំនេះដឹងច្រើនជាងកាលពីមុន!!
ក៖
អញ្ចឹងបើពេលកាលពីឆ្នាំមុនមកដល់ឥឡូវតើជីវភាពក្រុមគ្រួសារបងមានលក្ខណៈ
ម៉េចដែរបង?
ខ៖ បើនិយាយពីជីវភាពមិនជាណាស់អីទេគ្រាន់តែវាល្មម
បើវាប្រៀបធៀបកាលពីមុនមកវារៀងគ្រាន់បើបន្តិចទេបាទ!!
ក៖ ចំា!!កាលបងពីនៅក្មេង
បងចូលចិត្តលេងល្បែងអឺគេកាលពីពេលបងនៅក្មេងហ៉ា??
ខ៖ កាលពីខ្ញុំនៅក្មេងល្បែងដែលខ្ញុំចូលចិត្តលេងជាងគេគឺខ្ញុំចូលចិត្តលេងបាល់!!
ក៖ចំាលេងបាល់!!ចូលចិត្តលេងបាល់?ខ៖បាទ!!ក៖មានតែបាល់មួយទេបងណោះ?
ខ៖បាទក្រៅពីលេងបាល់ញ៉ាមលេងទាត់សីហើយនឹងពេលយប់ឡើងខែភ្លឺលេងក្រុង
មាន់ ពេលចូលឆ្នាំលេងបិតពួន ល នឹងល។
ក៖ ល នឹង ល!!
អញ្ចឹងបងទាក់ទងទៅនឹងអាហារតើបងចេះចំអិនម្ហូបអាហារទេបង?
ខ៖ ខ្ញុំអត់ចេះធ្វើផង។
ក៖ ហ្ហ៉ាអត់ចេះទេបង?
ខ៖អត់ចេះ!!
ក៖
ក្រៅពីជំនាញគ្រូបង្រៀនមានជំនាញអីគេទៀតដែលយកមកអនុវត្តដើម្បីជួយដ
ល់ ឬក៏អាចជួយដល់ជីវភាពជីវិតយើងបានទេ?
ខ៖
ក្រៅពីជំនាញបង្រៀនញ៉ាមដូចជាមិនចេះស្អីគេអីទៀតទេព្រោះអីខ្ញុំអត់បានរៀន
ព្រោះអីញ៉ាមគិតថាញ៉ាមរៀនភាសាអង់គ្លេសហ្នឹងព្រោះអីដើម្បីបង្កើនចំនេះដឹងនឹង
បង្កើនជីវភាពប៉ុន្តែត្រង់ថាបង្កើនតាមវិធីណានោះញ៉ាមអត់ដឹងបាទបាទ!!
ក៖អញ្ចឹងបងចេះការសាងសង់ផ្ទះការធ្វើអើរ
ការដាំបន្លែដូចថាអាជំនាញដែលយើងតិចតួចដែលយើងចេះហ៉ាបងចេះទេ?
ខ៖ ហ្ហ៉ាអាហ្នឹងរាល់ថ្ងៃញ៉ាមកំពុងតែដាំបន្លែនៅផ្ទះញ៉ាម!!
ក៖ ហ្ហ៉ាមានដាំបន្លែដែរ!!

ខ៖ បាទខាត់ណា ឆៃថាវ ត្រកូន លួង
បាទរាល់ថ្ងៃកំពុងតែមានបន្លែជាច្រើនមុខនៅក្នុងរបងផ្ទះរបស់ញ៉ុមហ្នឹងហ៉ាដើម្បីជួយកាត់បន្ថយការទិញរបស់ពីផ្សារហើយអើរនិយាយរួមចង់អោយមានពណ៍បៃតងនៅក្នុងផ្ទះ។
ក៖
ចង់បងញ៉ុមចង់សួរបងមួយឥឡូវបងមានអាយុ៤០ឆ្នាំហើយហើយក៏មានបញ្ហាច្រើននៅក្នុងជីវិតរបស់បងដែរ តើបងអាចចែកចាយនូវ
ថាបងមានឧបសគ្គដែលនៅក្នុងជីវិតដែលសំខាន់ដែលអាចធ្វើអោយបងចងចាំហ៉ា?
ខ៖
បាទមួយរយ:កាលកន្លងមកគ្មានអ្វីដែលគួរអោយចង់ចាំដែលជាឧបសគ្គសំរាប់ខ្ញុំទេព្រោះអីដំនើរជីវិតរបស់ខ្ញុំគឺរស់មកខ្ញុំមិនដែលប្រព្រឹត្តអីដែលគួរអោយខុសឆ្គងដូច្នោះគ្មានអ្វីដែលគួរអោយញ៉ុមព្រួយបារម្ភ។
ក៖ ដូចថាបញ្ហា
ជួនកាលម៉ាក់មានកូនដល់ទៅ៧នាក់រស់នៅក្នុងបន្ទុកជួនកាលយើងអាចចងចាំពីស្ថានភាពមួយហ្នឹងអ៊ីចឹងណាស់បង!!ខ៖ហ្ហ៉!ក៖នេះគឺជាបញ្ហាប្រឈមនឹងជីវិតយើងដែរ!!
ខ៖
បាទ!!ក៖ហ្នឹងហើយ!!ខ៖បាទបាទ!!ទាក់ទងទៅនឹងការចងចាំទាក់ទងទៅនឹងឆ្នាំ
១៩៨៩ ៨៩ ៩០
ឬក៏លោកឱពុកខ្ញុំគាត់ទឹមតែស្លាប់គឺការចងចាំគឺមានការខ្វះខាតនៅក្នុងក្រុមគ្រួសារខ្វះអាហាររូបតម្ភដោយសារម្តាយមិនអាចទៅលក់ដូរឆ្វាយៗដើម្បីយកប្រាក់កំរៃមកផ្គត់ផ្គង់ពួកខ្ញុំប៉ុន្តែធ្វើម៉ែចបើជីវភាពយើងទីទាល់ក្រនៅពេលនោះអ៊ីចឹងយើងត្រូវធ្វើម៉ែចអោយបានល្អជាងនោះហើយអញ្ចឹងការចងចាំញ៉ុមមានតែប៉ុណ្ណឹង!!បាទ!!
ក៖ អញ្ចឹងនៅពេលហ្នឹងហ៉ា
ក្រុមគ្រួសារបងដែលមានថ្ងៃណាដែលអត់មានបាយញ៉ុទេបង?
ខ៖ មានថ្ងៃមួយផ្ទះញ៉ុមអត់មានអង្ករទេ
ដើររកខ្ចីអង្ករអ្នកជិតខាងនៅក្នុងអំឡុងឆ្នាំ១៩៨៣ ៨៣
ក្នុងពេលនោះហើយដែលជីវភាពគ្រួសារញ៉ុមលំបាកដោយសារអត់ពីឱពុកខ្ញុំទៅ។
ក៖ ចាំអញ្ចឹងអរគុណបង
អញ្ចឹងញ៉ុមចង់សួរមួយទាក់ទងទៅហ្នឹងបទពិសោធន៍ដីល្អបំផុតរបស់បងគិតថាដែលជារឿងដែលរីករាយសំរាប់ជីវិតរបស់បងគឺជាពេលណាដែរបង?
ខ៖
បាទជីវិតដ៏រីករាយរបស់ខ្ញុំគឺនៅពេលដែលខ្ញុំបានចេញទៅសិក្សានៅប្រទេសក្រៅហ្នឹងគឺធ្វើអោយខ្ញុំរីករាយបាទព្រោះខ្ញុំមិននឹកស្មានថាក្រសួងអប់រំអោយដាក់ឈ្មោះរបស់ខ្ញុំបានទៅក្រៅទៅសិក្សានៅប្រទេសម៉ាឡេស៊ីមួយខែនេះសោះ
ដល់ពេលលឺដំណឹងនេះពេលក្រសួងដាក់អោយមកធ្វើអោយខ្ញុំមានអារម្មណ៍រីករាយរំភើបនឹងសប្បាយចិត្តតែម្តងបាទ!!
ក៖ហ្ហ៉!!អ៊ីចឹងមានតែកន្លែងហ្នឹងដែលធ្វើអោយបងចងចាំនឹងរីករាយបំផុត !!
អញ្ចឹងបងនេះជាអ្វីមួយដែលយើងចង់ចែកចាយ
ដូចថាបងមានកូនចង់អើរចង់ប្រាប់ទៅកូននៅពេលដែលគាត់ឣសំដីរបស់បងអញ្ចឹងហ៉ា?
ខ៖
អញ្ចឹងអ្វីដែលខ្ញុំចង់ប្រាប់កូនខ្ញុំពីវិជ្ជានឹងតំលៃនៃការសិក្សាញ៉ុមតែងតែប្រាប់កូនទាំងពីរអោយវាអោយខិតខំរៀនយកតំរាប់តាមឱពុកយកតំរាប់តាប៉ាព្រោះប៉ានៅធ្វើការហើយប៉ាប្រឹងរៀនធ្វើកិច្ចការដែលគ្រូបានដាក់ហើយយកអោយលោក

ក្រូទៀត អញ្ជឹងកូនឯងខំប្រឹង ទោះថាវិជ្ជា
វិជ្ជាគឺជាប្រទីបបំភ្លឺផ្លូវ បើគ្មានវិជ្ជាទេវាគ្មានអនាគត
ហើយការងារកូនកំលុបាកដែរ ហើយបើកូនមានចំនេះវិជ្ជាអាចអោយកូនមានចំនេះវិជ្ជាការងារកូនទៅនិយាយរួមទៅគឺវាអាចល្អអាចរុងរឿងភ្លឺស្វាងទៅថ្ងៃអនាគត នេះគឺជាចំនុចដែលញ៉ាមតែងតែអប់រំទូន្ទាន ចែកចាយទៅកូនរបស់ខ្ញុំ ។
ក៖
អញ្ជឹងបងតើបងចង់ចែកចាយអីគេខ្លះទាក់ទងទៅនឹងក្រុមគ្រួសារបងចំនុចល្អដែលបងបានរៀនពីក្រុមគ្រួសារបង
ហើយថាក្រុមគ្រួសារបានធ្វើអោយបងក្លាយជាមនុស្សល្អអញ្ជឹងណាស់បង?
ខ៖អ្វីដែលខ្ញុំចង់ចែកចាយទៅកាន់គ្រួសារខ្ញុំគឺខ្ញុំតែងតែអប់រំដល់បងៗរបស់ខ្ញុំ
រាល់ថ្ងៃបងៗរបស់ខ្ញុំហ្នឹងតែងតែចាត់ទុកខ្ញុំហ្នឹង តែងតែគោរពខ្ញុំទៅវិញ
ព្រោះអីខ្ញុំតែងតែមានភាពយុត្តិធម៏សំរាប់ទៅលើបងប្អូនញ៉ាមទាំងអស់ហើយខ្ញុំត្រូវតែគោរពម្តាយហើយមិនឈ្លោះជាមួយគាត់ហើយបើមើលទៅប្អូនណាដែលគាត់មិនសូវជាស្តាប់ហ្នឹងម្តាយ !! នេះជាចំនុចអោយគាត់យកទៅជាគំរូសព្វថ្ងៃនេះ!!
ក៖ អញ្ជឹងបងទាក់ទង អញ្ជឹងរាងសួររាងចាកបន្ទិច អញ្ជឹងទាក់ទងទៅនឹង
អញ្ជឹងបងដែលឮទាក់ទងទៅហ្នឹងព្រះយេស៊ូវគ្រីស្ទទេបង?
ខ៖ យេស៊ូវគ្រីស្ទញ៉ាមដែរឮ។
ក៖ឮ!!
ខ៖បាទ!!ក៖ចាំអញ្ជឹងបងដែលជួបអ្នកផ្សព្វផ្សាយសាសនាដែលគេហៅថាអ៊ែលឌើរ ស៊ីស្ទើរទេ?
ខ៖ ខ្ញុំអត់ដែលជួបទេ តែធ្លាប់ឮគិចៗអំពីពត៏មានហ្នឹង!!អត់ដែលជួបទេ!!
ក៖ អញ្ជឹងបងអរគុណសំរាប់ការចែកចាយ!!ខ៖បាទ!!ខ៖នូវ
ហើយខ្ញុំមានអំណរគុណដែលបងបានចែកចាយបទពិសោធន៏ល្អៗទាក់ទងទៅនឹងប្រវត្តិក្រុមគ្រួសារបងបានចែកចាយ
បងបានអើរចែកចាយពីឆ្នាំជាក់លាក់ហើយពួកយើងពិតជារីករាយដែលបានដឹងអំពីប្រវត្តិក្រុមគ្រួសាររបស់បងហើយខ្ញុំមានតែប៉ុណ្ណឹងហើយខ្ញុំជំរាបលាបង។
ខ៖ បាទ !
អរគុណដល់សុម៉ាលីដែលបានសំភាសន៏ខ្ញុំដែលខ្ញុំបានអើរឆ្លើយនូវសំនួរសុម៉ាលីទាំងអស់
តែគ្រាន់តែថាខុសឆ្គងត្រង់ណាសូមអធ្យាស្រ័យព្រោះនេះជាចំលើយដែលញ៉ាមអត់បានត្រៀមទុកទេបាទ!!
ក៖ អរគុណបងនេះជាពេលវេលាល្អសំរាប់រៀនទៅដល់អ្នកដទៃផ្សេងទៀត
ជំរាបលា!!
ខ៖ ជំរាបលា។
ក៖ អរគុណបង។